សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# កំណែទម្រង់រដ្ឋបាលថ្នាក់ ឃុំ សង្កាត់

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **គង់ ស្រីតូ**

សាស្ត្រាចារ្យណែនាំ
លោក **ម៉ៅ បុណ្ណា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី ១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គង់ ស្រីតូ** ជានិស្សិតបរិញ្ញាបត្រផ្នែករដ្ឋបាលសាធារណៈជំនាន់ទី១២ ឆ្នាំសិក្សា ២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាដំបូងនាងខ្ញុំសូមលំឱនកាយក្រាបប្រណិប័ត និងសំដែងកតញ្ញូតាធម៌កតវេទីយ៉ាងជ្រាលជ្រៅ ជូនចំពោះលោកឪពុក **គង់ សុផល** អ្នកម្តាយ **ព្រំ ផា** ដែលលោកមានគុណទាំងពីរបានផ្តល់កំណើត ដល់កូន ហើយបានចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តី និងបានផ្គត់ផ្គង់ឱ្យកូនទាំងផ្នែក ស្មារតី និងសម្ភារៈសម្រាប់ការសិក្សា និងជួយទំនុកបម្រុងជាពិសេសបានផ្តល់កម្លាំងចិត្ត និងភាពកក់ក្តៅ ដល់ រូបកូនប្រកបដោយព្រហ្មវិហារធម៌រហូតដល់ពេលបញ្ចប់ថ្នាក់ឧត្តមសិក្សាដោយទទួលបានលទ្ធផល គួរជាទីមោទនៈភាព។

## សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជ្រោមជ្រែង និងលើកទឹកចិត្ត ដល់រូបនាងខ្ញុំកន្លងមក។ លោកសាស្ត្រាចារ្យណែនាំ **ម៉ៅ មុន្នីណា** ដែលបានយកចិត្តទុកដាក់ចំណាយ ទាំងពេលវេលា ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ប្រាជ្ញាស្មារតីអំពីវិធីសាស្ត្រ និងរបៀបនៃការសរសេរអត្ថ បទ កែតម្រូវ អត្ថន័យ អក្ខរាវិរុទ្ធ និងផ្តល់គំនិតល្អៗសម្រាប់តាក់តែងរៀបរៀងអត្ថបទសារណានេះ។

ជាទីបញ្ចប់ នាងខ្ញុំសូមឧទ្ទិសដល់បារមីវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រសិទ្ធិពរជ័យ សេរីមង្គលបវរ មហាប្រសើរ សូមកើតមានចំពោះ លោកអ្នកមានគុណ បងប្អូន សាច់ញាតិ លោក លោកស្រី សាស្ត្រា ចារ្យ លោកគ្រូ អ្នកគ្រូ និងក្រុមគ្រួសារឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាយើងសព្វថ្ងៃជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយការគ្រប់គ្រងនៅមានកម្រិត ដូចនេះហើយរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងបង្កើតយុទ្ធសាស្ត្រថ្មីៗជាច្រើនដើម្បីធានាឱ្យបានការគ្រប់គ្រងមាននិរន្តភាព។ ក្នុងនោះមានដូចជាការធ្វើកំណែទម្រង់រដ្ឋបាលដែនដីថ្នាក់ក្រោមជាតិ ដែលជា ការកែទម្រង់រដ្ឋបាលថ្មីនេះបានខិតជិតជាមួយនឹងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈបង្កើនសុខុមាលភាព និងឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានហើយធ្វើឱ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និតគ្នាមិនតែប៉ុណ្ណោះយល់កាន់តែច្បាស់ពីតម្រូវការរបស់ប្រជាពលរដ្ឋថាពួកគាត់ចង់បានអ្វី ឬមិនចង់បានអ្វី និងងាយស្រួលក្នុងការជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបានទាន់ពេលវេលា។ ហេតុដូច្នេះហើយទើបនាងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទមួយស្តីពី "**កំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់**" ដើម្បីសរសេរសារណាបញ្ចប់ការសិក្សា និងបង្ហាញឱ្យឃើញពីរបៀប នៃការកែទម្រង់រដ្ឋបាលដែនដីថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈល្អ។ តាមរយៈប្រធានបទមួយនេះនាងខ្ញុំបានព្យាយាម និងចំណាយពេលវេលាជាច្រើនដើម្បីស្វែងរកឯកសារដែលពាក់ព័ន្ធមកចងក្រងជាសៀវភៅនេះឡើង។ ចំពោះការចងក្រងសៀវភៅនេះនាងខ្ញុំក៏មានបំណងចូលរួមចំណែកផងដែរ ក្នុងការចូលរួមអភិវឌ្ឍធនធានមនុស្សឱ្យស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងការកាត់បន្ថយភាពក្រីក្រ។

ដូច្នេះនាងខ្ញុំសង្ឃឹមថាសារណានេះនឹងជួយដល់ស្មារតី និងជាមូលដ្ឋានខ្លះៗដល់អ្នកសិក្សាស្រាវជ្រាវដែលមានបំណងចង់ស្វែងយល់បញ្ហាពាក់ព័ន្ធនឹងប្រធានបទនេះ។ បើទោះជាយ៉ាងណាក្តីនាងខ្ញុំជឿជាក់ថាការចងក្រងសៀវភៅនេះឡើងនៅតែមានចំណុចខ្វះខាតជាមិនខានឡើយទាំងផ្នែកខ្លឹមសារ និងអក្ខរាវិរុទ្ធ។ នាងខ្ញុំរីករាយនឹងទទួលយកការរិះគន់ស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានគ្រប់រូបដើម្បីកែលម្អឱ្យកាន់តែប្រសើរនៅពេលក្រោយៗទៀត។

ជាចុងក្រោយនាងខ្ញុំសូមប្រសិទ្ធិពរ ដល់មិត្តអ្នកអានទាំងអស់ឱ្យជួបតែសេចក្តីសុខគ្រប់ប្រការ និងសូមឱ្យទទួលបានការគោរពស្រឡាញ់ពីនាងខ្ញុំ។

# មាតិកា

**សេចក្តីផ្តើម** **ទំព័រ**

**១. លំនាំបញ្ហានៃការស្រាវជ្រាវ**..........១
**២. ចំណោទបញ្ហានៃការស្រាវជ្រាវ**..........១
**៣. គោលបំណងនៃការស្រាវជ្រាវ**..........២
**៤. ដែនកំណត់នៃការស្រាវជ្រាវ**..........២
**៥. សារៈសំខាន់នៃការស្រាវជ្រាវ**..........២
**៦. វិធីសាស្ត្រនៃការស្រាវជ្រាវ**..........២
**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**..........២

## ជំពូកទី១

## សញ្ញាណទូទៅនៃការអនុវត្តប្រព័ន្ធវិមជ្ឈការ

**ផ្នែកទី១ ៖ និយមន័យ និងគោលការណ៍នៃវិមជ្ឈការ**..........៤
១.១ ៖ និយមន័យប្រព័ន្ធវិមជ្ឈការ..........៤
១.២ ៖ គោលការណ៍នៃប្រព័ន្ធវិមជ្ឈការ..........៤
ក. ស្វ័យភាពរដ្ឋបាល..........៥
ខ. ស្វ័យភាពហិរញ្ញវត្ថុ..........៦
១.៣ ៖ ចរឹកលក្ខណៈនៃវិមជ្ឈការ..........៧
**ផ្នែកទី២ ៖ ប្រភេទនៃវិមជ្ឈការ**..........៨
២.១ ៖ វិមជ្ឈការនយោបាយ..........៩
២.២ ៖ វិមជ្ឈការរដ្ឋបាល..........៩
២.៣ ៖ វិមជ្ឈការសារពើពន្ធ..........៩
**ផ្នែកទី៣ ៖ គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើវិមជ្ឈការ**..........១០
៣.១ ៖ គុណសម្បត្តិ..........១០
៣.២ ៖ គុណវិបត្តិ..........១១

## ជំពូកទី២
## រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ឃុំ សង្កាត់

**ផ្នែកទី១ ៖ ការរៀបចំក្រុមប្រឹក្សាឃុំ សង្កាត់**............................................................១១
១.១ ៖ ក្រុមប្រឹក្សាឃុំ សង្កាត់..........................................................................................១១
១.២ ៖ ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់..............................................................................១១
ក. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត.....................................................១១
ខ. លក្ខខណ្ឌបេក្ខជនឈរឈ្មោះបោះឆ្នោត..................................................................១១
គ. ការតែងតាំងក្រុមប្រឹក្សាឃុំ សង្កាត់........................................................................១៣
ឃ. តួនាទី និងសិទ្ធិអំណាចរបស់ឃុំ សង្កាត់.................................................................១៣
១. តួនាទីរបស់ឃុំ សង្កាត់.............................................................................១៣
២. សិទ្ធិអំណាចរបស់ឃុំ សង្កាត់......................................................................១៤
**ផ្នែកទី២ ៖ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**............................................................១៥
២.១ ៖ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់....................................................................................១៥
ក. មេឃុំ ចៅសង្កាត់...................................................................................................១៥
ខ. ជំទប់ ឬចៅសង្កាត់រង.............................................................................................១៥
គ. គណៈកម្មាធិការ.....................................................................................................១៥
ឃ. ស្មៀនឃុំ សង្កាត់...................................................................................................១៦
ង. មេភូមិ...................................................................................................................១៦
២.២ ៖ តួនាទីសិទ្ធិអំណាច និងការទទួលខុសត្រូវ.....................................................................១៧
ក. មេឃុំ ចៅសង្កាត់...................................................................................................១៧
ខ. ជំទប់ ឬចៅសង្កាត់រង.............................................................................................១៨
គ. គណៈកម្មាធិការ.....................................................................................................១៨
ឃ. ស្មៀនឃុំ សង្កាត់...................................................................................................១៨
ង. មេភូមិ...................................................................................................................១៨

## ជំពូកទី៣
## កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ផ្នែកទី ១ ៖ គោលការណ៍គ្រឹះ**..........២០
១.១ ៖ ចក្ខុវិស័យ..........២០
១.២ ៖ គោលបំណង..........២០
១.៣ ៖ គោលដៅ..........២០
ក. សេវាសាធារណៈ..........២០
ខ. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស..........២១
គ. បៀវត្ស និងប្រាក់ឧបត្ថម្ភ..........២១
១.៤ ៖ យុទ្ធសាស្ត្រ..........២១
ក. សេវាសាធារណៈ..........២១
ខ. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស..........២២
គ. បៀវត្ស និងប្រាក់ឧបត្ថម្ភ..........២២
១.៥ ៖ បញ្ហាប្រឈម និងដំណោះស្រាយ..........២២
ក. សេវាសាធារណៈ..........២២
ខ. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស..........២៣
គ. បៀវត្ស និងប្រាក់ឧបត្ថម្ភ..........២៣
**ផ្នែកទី ២ ៖ គម្រោងថវិការដ្ឋ**..........២៤
២.១ ៖ ការលើកផែនការយុទ្ធសាស្ត្រ..........២៤
ក. ចំណូល..........២៤
ខ. ចំណាយ..........២៥
គ. ដំណើរការថវិកា ឃុំ សង្កាត់..........២៥
២.២ ៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធ..........២៦

**សេចក្ដីសន្និដ្ឋាន**........................................................................................................២៧
**អនុសាសន៍**................................................................................................................២៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺត្រូវបានមនុស្សនៅក្នុងសកលលោកទទួលស្គាល់ថាជាប្រទេសដែលមានវប្បធម៌ និងអរិយធម៌សុះសាយនៅអាស៊ីអាគ្នេយ៍។ ប៉ុន្តែជាអកុសលនៅក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ កម្ពុជាត្រូវបានជួបប្រទះនៅវិបត្តិសង្គ្រាមប្រល័យពូជសាសន៍សាហាវយោងខ្នងដែលជារបបផ្ដុលនិយមសម្លាប់ពូជសាសន៍ និងបំផ្លាញសាសនាខ្លួនឯង។ ក្រោយពីសង្គ្រាមត្រូវបានបញ្ចប់ប្រទេសកម្ពុជាត្រូវបានទទួលរងនូវការបំផ្លាញយ៉ាងច្រើនដូចជា ហេដ្ឋារចនាម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងបញ្ញវន្ដដែលជាកម្លាំងស្នូលនៃធនធានមនុស្សមិនអាចខ្វះបានក្នុងការអភិវឌ្ឍប្រទេសជាតិ។

ជាការពិតណាស់កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ សង្កាត់) មានគោលបំណងធ្វើឱ្យកាន់តែមានភាពឆ្លើយតប ប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្ត ព្រមជាមួយការលើកកម្ពស់សេវាសាធារណៈបណ្ដុះបណ្ដាលធនធានមនុស្ស ឆន្ទៈ ម្ចាស់ការ ភក្ដីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការ ដើម្បីប្រែក្លាយជារដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្ដល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។ មួយវិញទៀត អភិបាលកិច្ចល្អ ត្រូវបានចាត់ជាស្នូលសម្រាប់ជោគជ័យនៃដំណើរការកែទម្រង់របស់រាជរដ្ឋាភិបាល និងសង្គមជាតិទាំងមូល។ ដោយឡែកតម្រូវការរបស់ប្រជាពលរដ្ឋបច្ចុប្បន្ន គឺការដោះស្រាយបញ្ហាផ្សេងៗ ទាន់ពេលវេលាពីសំណាក់មន្ត្រីឃុំ សង្កាត់ ប៉ុន្តែដោយសារការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ សង្កាត់) នៅមានកម្រិតនៅឡើយ។ ហេតុនេះហើយទើបបានជារាជរដ្ឋាភិបាលសម្រេចធ្វើការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងការអភិវឌ្ឍឃុំ សង្កាត់។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាពីប្រធានបទខាងលើ អំពីកំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ បង្ហាញឱ្យឃើញបញ្ហាចោទដូចខាងក្រោម៖

- តើយើងគួរធ្វើអ្វីខ្លះ និងដោយរបៀបណា ដើម្បីឈានទៅសម្រេចកម្មវិធីកំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់?
- តើប្រជាពលរដ្ឋទទួលបានអ្វីខ្លះ ក្រោយពេលធ្វើការកែទម្រង់?
- តើការកែទម្រង់ជួបនូវបញ្ហាប្រឈមអ្វីខ្លះ ហើយអាជ្ញាធរមានសមត្ថកិច្ចមានដំណោះស្រាយយ៉ាងណាជូនដល់ប្រជាពលរដ្ឋ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវនូវប្រធានបទខាងលើ មានគោលបំណងផ្ដោតសំខាន់ទៅលើការធ្វើកំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់មាន២ចំនុចះ

- ការសិក្សាពីទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ
- ការសិក្សាពីរចនាសម្ព័ន្ធថ្នាក់ឃុំ សង្កាត់
- កំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ បញ្ហាប្រឈម និងដំណោះស្រាយ

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺសំដៅលើការធ្វើកំណែទម្រង់ថ្នាក់ឃុំ សង្កាត់ដោយវិធីណាទើបប្រកបដោយប្រសិទ្ធភាព តម្លាភាព ភាពយុត្តិធម៌ និងឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ យ៉ាងណាមិញការស្រាវជ្រាវនេះផ្ដោតសំខាន់លើ «កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨» និងមិនបានយកទៅប្រៀបធៀបនឹងប្រទេសដទៃឡើយ។

## ៥. សារៈសំខាន់ក្នុងការស្រាវជ្រាវ

លទ្ធផលដែលទទួលបានក្នុងការស្រាវជ្រានូវប្រធានបទខាងលើ គឺបានផ្ដល់អត្ថប្រយោជន៍យ៉ាងច្រើនដូចជា ចំណេះដឹង គោលការណ៍ និងការផ្ដល់ជាឯកសារបន្ថែមសម្រាប់ឱ្យនិស្សិត ប្រជាពលរដ្ឋទាំងអស់បានយល់ដឹងកម្មវិធីកំណែទម្រង់រដ្ឋបាលនៅក្នុងប្រទេសរបស់ខ្លួន។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ដើម្បីប្រមូលព័ត៌មានមកសរសេរ និងចងក្រងជាសារណានេះឱ្យកាន់តែល្អប្រសើរ គឺមានសកម្មភាពស្រាវជ្រាវដូចជាះ

- មេរៀន និងទ្រឹស្តីដែលបានសិក្សាកន្លងមកព្រមទាំងការពន្យល់ពីសាស្ត្រាចារ្យ
- ប្រមូលពត៌មាននៅបណ្ណាល័យ និងបណ្ណាគារ
- ដកស្រង់ពីសៀវភៅខ្លះដែលពាក់ព័ន្ធនឹងប្រធានបទ
- ស្រាវជ្រាវទាញយកពីប្រព័ន្ធអេឡិចត្រូនិច ( អ៊ីនធើណែត ... )

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការបកស្រាយប្រធានបទ «កំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់» នាងខ្ញុំធ្វើការបែងចែកដូចតទៅះ

- មាតិកា
- សេចក្ដីផ្ដើម

- ជំពូកទី១ ៖ ជំពូកនេះ គឺសិក្សាពីសញ្ញាណទូទៅនៃការអនុវត្តប្រព័ន្ធវិមជ្ឈការដូចជា និយមន័យ គោលការណ៍នៃប្រព័ន្ធវិមជ្ឈការ ប្រភេទនៃប្រព័ន្ធវិមជ្ឈការ គុណសម្បត្តិ និងគុណវិបត្តិនៃការគ្រប់គ្រងតាមបែបវិមជ្ឈការ។
- ជំពូកទី២ ៖ ជំពូកនេះ គឺបង្ហាញពីការប្រព្រឹត្តទៅនៃរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ឃុំ សង្កាត់ដូចជា ការរៀបចំក្រុមប្រឹក្សាឃុំ សង្កាត់ និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់រាប់ចាប់ពីប្រធានក្រុមប្រឹក្សា (ចៅសង្កាត់) រហូតដល់មេភូមិ។
- ជំពូកទី៣ ៖ ជំពូកនេះ គឺសិក្សាពីការធ្វើកំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ដូចជា គោលការណ៍គ្រឹះដែលទាក់ទងនឹងចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រក្នុងការធ្វើកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព និងតាមរយៈគម្រោងថវិការដ្ឋ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការអនុវត្តប្រព័ន្ធវិមជ្ឈការ

## ផ្នែកទី១ ៖ និយមន័យ និងគោលការណ៍នៃវិមជ្ឈការ

### ១.១ ៖ អត្ថន័យនៃវិមជ្ឈការ

គេបានឱ្យនិយមន័យលើការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការថា គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលដែលរដ្ឋបាលកណ្តាលផ្ទេរអំណាចទៅឱ្យដូចជា រដ្ឋបាលឃុំ-សង្កាត់។ ចំពោះការផ្ទេរអំណាចបែបនេះមានគោលបំណងឱ្យរដ្ឋបាលមូលដ្ឋានទទួលខុសត្រូវលើកិច្ចការណាដែលជាផលប្រយោជន៍របស់ខ្លួនដែរ។

តាមន័យបច្ចេកទេសគតិយុត្ត វិមជ្ឈការ គឺជាការបង្កើតនីតិបុគ្គលដាច់ចេញពីរដ្ឋ ដែលមានសមត្ថកិច្ចផ្ទាល់ពោល គឺនីតិបុគ្គលនេះប្រតិបត្តិសមត្ថកិច្ចខ្លួនដោយរបៀបស្វយ័ត។ បច្ចេកទេសនៃការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការមានលក្ខណៈពិសេសបីគឺ៖

- បុគ្គលភាពគតិយុត្ត
- សមត្ថកិច្ចផ្ទាល់
- ការទទួលបានស្វ័យភាពកំណត់។

រដ្ឋបាលវិមជ្ឈការមានបុគ្គលភាពគតិយុត្តខុសពីរដ្ឋ ពោលគឺ អង្គការនេះជាប្រធាននៃនីតិផ្សេងពីរដ្ឋ។ អង្គការនេះមានសិទ្ធិ កាតព្វកិច្ច គោលដៅ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ បន្ថែមពីលើនេះ រដ្ឋបាលវិមជ្ឈការទទួលបានសមត្ថកិច្ចកំណត់ដោយច្បាប់ពោល គឺមានឯកភាពពីរដ្ឋ ដូច្នេះក្រោយពេលកំណត់សមត្ថកិច្ចឱ្យទៅរដ្ឋបាលវិមជ្ឈការរដ្ឋមិនអាចចូលធ្វើអន្តរាគមន៍បានទេ។ ជាចុងក្រោយរដ្ឋបាលវិមជ្ឈការទទួលបាននូវស្វ័យភាពដែលធ្វើឲ្យខ្លួនមិនស្ថិតក្រោមអំណាចឋានុក្រម។ ប៉ុន្តែជាតថភាព ស្វ័យភាពនេះមិនឯករាជ្យទេ ដោយសាររដ្ឋបាលកណ្តាលនៅតែមានសិទ្ធិប្រើអំណាចត្រួតពិនិត្យក្នុងនាមជាអាណាព្យាបាល ឬតាមរយៈស្ថាប័នតុលាការ។

ជាការពិតប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការនេះ គឺមានខ្លឹមសារជាការអនុវត្តលទ្ធិប្រជាធិបតេយ្យជម្រុញឱ្យមានអភិបាលកិច្ចល្អ និងលើកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យល្អដោយសាររដ្ឋអំណាចបានធ្វើការផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ។ នៅក្នុងកាលានុវត្តភាពនេះរដ្ឋអាចស្គាល់ និងជ្រួតជ្រាបពីការលំបាក ទុក្ខធុរៈ និងតម្រូវការរបស់ប្រជារាស្ត្រជាហេតុធ្វើឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ និងកែលម្អយុទ្ធសាស្ត្រដឹកនាំឱ្យកាន់តែមានប្រសិទ្ធភាព។

### ១.២ ៖ គោលការណ៍នៃវិមជ្ឈការ

ការគ្រប់គ្រងតាមប្រព័ន្ធវិមជ្ឈការ គឺបានផ្តល់អំណាចសម្រេចស្វយ័តឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលកើតចេញពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋមានសិទ្ធិសម្រេចលើគ្រប់បញ្ហា និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

នៅតាមដែនដីដែលស្ថិត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការធ្វើវិមជ្ឈការនេះគឺ រដ្ឋមិនប្រមូលផ្ដុំអំណាចតែម្នាក់ឯងទេ ដោយរដ្ឋតែងតែបង្កើតឱ្យមានសមូហភាព តាមរយៈការបង្កើតនីតិបុគ្គលជាច្រើនទៀតដែលមានអំណាចរដ្ឋបាលសម្រេចដោយស្វ័យភាពរាល់កិច្ចការដែលជាផលប្រយោជន៍ទូទៅរបស់ពលរដ្ឋនៅក្នុង សមូហភាពនោះ ផ្ទាល់។

ការធ្វើវិមជ្ឈការ ជាគោលការណ៍មូលដែលរដ្ឋបាលថ្នាក់ជាតិបានផ្ដល់ស្វ័យភាពមួយចំនួនឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយស្វ័យភាពសំខាន់ទាំងនោះរួមមានៈ

- ស្វ័យភាពរដ្ឋបាល
- ស្វ័យភាពហរិញ្ញវត្ថុ

**ក. ស្វ័យភាពរដ្ឋបាល**

ស្វ័យភាពរដ្ឋបាល គឺជាគោលការណ៍មួយដែលរដ្ឋបាលថ្នាក់ជាតិប្រគល់ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្ត និងគ្រប់គ្រងដែនដីរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។

គោលការណ៍នេះ មានន័យថារដ្ឋបាលថ្នាក់ជាតិអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការគ្រប់គ្រងក្នុងរដ្ឋបាលរបស់ខ្លួនដោយស្វយ័តយ៉ាងពេញលេញ។

យ៉ាងណាមិញបើយោងតាមឯកសារបឋកថារបស់ឯកឧត្តម ព្រុំ សុខា រដ្ឋលេខធិការក្រសួងមហាផ្ទៃនៅសាលាភូមិន្ទរដ្ឋបាលនាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ បានលើកឡើងថាវិមជ្ឈការទាល់តែៈ

- មានក្រុមប្រឹក្សាកើតឡើងដោយការបោះឆ្នោតថ្នាក់ជាតិ ឯកឧត្តមបានលើកឡើងថា វិមជ្ឈការត្រូវតែមានអាជ្ញាធរថ្នាក់ក្រោមជាតិមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ដើម្បីជាមធ្យោបាយក្នុងការអនុវត្តការងារតាមគោលការណ៍ វិមជ្ឈការអនុវត្តរដ្ឋបាលនានានៅថ្នាក់ក្រោមជាតិទាំងអស់ដែលបានបោះឆ្នោតជ្រើសរើស។ ចំណែកឯប្រទេសកម្ពុជាសព្វថ្ងៃបានអនុវត្ត រួចរាល់ហើយ រដ្ឋបាលវិមជ្ឈការនេះ បានដំណើរការ (បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០២ និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៩)
- រាជរដ្ឋាភិបាលផ្ទេរភាពជាម្ចាស់នៃមុខងារ វិមជ្ឈការតម្រូវឱ្យរាជរដ្ឋាភិបាលលះបង់ និងផ្ទេរភាពជាម្ចាស់នៃមុខងារសមស្របទៅក្រុមប្រឹក្សាដែលជាប់ឆ្នោត ប៉ុន្តែរាជរដ្ឋាភិបាលត្រូវត្រួតពិនិត្យមើលមុខងារទាំងនោះ ដើម្បីធានាថាសកម្មភាពរបស់ក្រុមប្រឹក្សាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយមិនធ្វើសកម្មភាពអ្វីដែលផ្ទុយ ឬប្រឆាំងនឹងផលប្រយោជន៍ជាតិ។
- ធនធានគ្រប់គ្រាន់ក្រុមប្រឹក្សាដែលជាប់ឆ្នោតត្រូវតែទទួលបានការផ្ទេរធនធានចាំបាច់ដើម្បីសម្រេចអនុវត្ត និងការគ្រប់គ្រងមុខងាររបស់ខ្លួនដែលធនធានទាំងនោះរួមមាន ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ។

បើពិនិត្យមើលហិរញ្ញវត្ថុមមានមូលនិធិរបស់ក្រុមប្រឹក្សាបានមកពីការផ្ទេរពីថ្នាក់ជាតិ ប៉ុន្តែក្រុមប្រឹក្សាក៏អាចរកចំណូលដោយខ្លួនឯងបានដែរ ហើយបញ្ហាទាំងអស់នេះត្រូវកំណត់ដោយច្បាប់ស្តីពី "ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ"។

- ស្វ័យភាពមូលដ្ឋាន និងគណនេយ្យភាពវិមជ្ឈការមានគោលបំណងផ្តល់ស្វ័យភាពមូលដ្ឋាន និងតម្រូវឱ្យក្រុមប្រឹក្សា ដែលជាប់ឆ្នោតធ្វើជាតំណាងឱ្យសហគមន៍មូលដ្ឋានរបស់ខ្លួន ហើយក្រុមប្រឹក្សាឆ្លើយតប និងមានគណនេយ្យភាព ចំពោះសហគមន៍មូលដ្ឋានរបស់ពួកគេលើការអនុវត្តមុខងាររបស់ខ្លួន។ ជាពិសេសទៅទៀតនោះគណនេយ្យភាពដំបូងជាមួយប្រជាពលរដ្ឋនៅមូលដ្ឋានព្រមទាំងមានគណនេយ្យភាពដែរជាមួយរាជរដ្ឋាភិបាលចំពោះសកម្មភាពក្នុងក្របខណ្ឌច្បាប់។ ម៉្យាងវិញទៀត ចាំបាច់ត្រូវទទួលស្គាល់ថាក្រុមប្រឹក្សាមានស្វ័យភាពមូលដ្ឋានក្នុងការអនុវត្តអាណត្តិ និងមុខងាររបស់ខ្លួន។ ក្រុមប្រឹក្សាត្រូវមានលទ្ធភាពក្នុងការពិភាក្សាការជជែកវែកញែក និងការសម្រេចចិត្តពីជម្រើសក្នុងការដោះស្រាយបញ្ហារបស់មូលដ្ឋាន។

- កិច្ចសហការគ្នា និងការពឹងផ្អែកគ្នាទៅវិញទៅមកវិមជ្ឈការមិនមែនមានន័យថាជាការផ្តាច់ក្រុមប្រឹក្សាពីថ្នាក់ជាតិ ឬអង្គភាពរបស់ថ្នាក់ជាតិ ឬពីថ្នាក់ផ្សេងៗនោះទេ។

- សនិទានភាពសម្រាប់វិមជ្ឈការ វិមជ្ឈការជាយុទ្ធសាស្ត្រអភិបាលកិច្ចមួយ។ ជាទូទៅសនិទានភាព (មូលហេតុ) ដែលមានការអនុម័តយកវិមជ្ឈការជាយុទ្ធសាស្ត្រមួយ រួមមាន៖

  - សេវាសធារណៈដែលមានការឆ្លើយតប
  - ធ្វើឱ្យប្រសើរដល់ប្រសិទ្ធភាពនៃសាធារណៈ
  - ធ្វើឱ្យប្រសើរការផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ
  - ផ្តល់កាលានុវត្តភាពដល់ប្រជាពលរដ្ឋ និងសហគមន៍ក្នុងការចូលរួមចំណែក

តាមគោលការណ៍វិមជ្ឈការនេះបានបង្ហាញពីស្វ័យភាពដែល រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានអំណាច និងធនធានគ្រប់គ្រាន់សម្រាប់ការអនុវត្តការងាររបស់ខ្លួនក្នុងការជួយប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា ពីព្រោះដោយសារអាជ្ញាធរនេះស្ថិតនៅកៀកនឹងប្រជាពលរដ្ឋ។

### ខ. ស្វ័យភាពហិរញ្ញវត្ថុ

ក្នុងការគ្រប់គ្រងរដ្ឋបាលឱ្យមានប្រសិទ្ធភាពរដ្ឋបាលថ្នាក់ជាតិបានប្រគល់សិទ្ធិអំណាច (ស្វ័យភាព) ផ្នែកហិរញ្ញវត្ថុ ដើម្បីជួយជំរុញដល់ដំណើរការរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែប្រសើរក្នុងគោលបំណងបំពេញតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

រដ្ឋបាលវិមជ្ឈការដែលទទួលបានស្វ័យភាពគឺមិនមែនមានន័យថាមានឯករាជ្យក្នុងការចេញសេចក្តីសម្រេចទេ ផ្ទុយទៅវិញរាល់សេចក្តីសម្រេចទាំងអស់ទោះទាក់ទងទៅនឹងវិស័យរដ្ឋបាលក៏ដូចជាវិស័យហិរញ្ញវត្ថុ គឺត្រូវស្ថិតក្នុងការត្រួតពិនិត្យពីសំណាក់អាជ្ញាធររដ្ឋថ្នាក់ជាតិដដែល គេហៅថាការត្រួតពិនិត្យជាបច្ឆាកាល (A posteriori)។

### ១.៣ ៖ ចរិតលក្ខណៈនៃប្រព័ន្ធវិមជ្ឈការ

ក្នុងការគ្រប់គ្រងតាមប្រព័ន្ធវិមជ្ឈការ ទោះបីជាទម្រង់នៃការរៀបចំនេះបានផ្ទេរទៅឱ្យសមូហភាពដែនដីសិទ្ធិអំណាចក្នុងការសម្រេចប្រកបដោយស្វ័យភាពក៏ដោយនៅមានកិច្ចការធំៗ និងសំខាន់ៗចាំបាច់ផ្សេងទៀតដែលអាជ្ញាធរកណ្តាលត្រូវរក្សាទុកផ្តាច់មុខមិនឱ្យអាជ្ញាធរ វិមជ្ឈការក្នុងការសម្រេចដដែលយើងឃើញមាន[1]៖

- កិច្ចការការពារជាតិ
- កិច្ចការសន្តិសុខជាតិ
- កិច្ចការការទូត
- កិច្ចការពាណិជ្ជកម្មក្រៅប្រទេស
- កិច្ចការបោះពុម្ពប្រាក់
- កិច្ចការតុលាការ
- កិច្ចការធ្វើច្បាប់
- កិច្ចការអត្រានុកូលដ្ឋាន
- និងវិស័យផ្សេងទៀតដែលច្បាប់រដ្ឋកំណត់។[2]

ប៉ុន្តែយើងសង្កេតជារឿយៗ ក្នុងការផ្ទេរអំណាចដោយកំណត់ក្នុងច្បាប់សមូហភាពវិមជ្ឈការភាគច្រើនវាថាពាក់ព័ន្ធខ្លាំងនឹងកិច្ចការ៖

- ផ្នែកសេដ្ឋកិច្ចតូចៗ
- វប្បធម៌
- សង្គមកិច្ច
- វិទ្យាសាស្ត្រ
- ជាពិសេសគឺកិច្ចការផ្នែកអភិវឌ្ឍតែម្តង។

វិមជ្ឈការដែនដីត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

ការទទួលស្គាល់ផលប្រយោជន៍រាស្ត្រប្រជាជន

**ផលប្រយោជន៍រាស្ត្រប្រជា**

ផលប្រយោជន៍ជាតិពិតជាមានសារៈសំខាន់ដល់រាស្ត្រប្រជាទាំងមូល។ ប៉ុន្តែក្នុងជីវភាពរស់នៅរបស់រាស្ត្រជាធម្មតាដូចជា ការមានផ្ទះសម្បែងការមានមុខរបរចិញ្ចឹមជីវិតការធ្វើដំណើរចុះឡើងការព្យាបាល ការរៀនសូត្រ

[1] សៀវភៅ **នីតិរដ្ឋបាលទូទៅ** របស់សាស្ត្រាចារ្យ **ហៀង សាង** បោះពុម្ពលើកទី១ ឆ្នាំ២០១១ ទំព័រ ១៣៩-១៤២។

[2] ទាំងនោះជាកិច្ចការផ្តាច់មុខរបស់រដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋាភិបាលកណ្តាល។

ការកំសាន្តក៏ដូចជាការធ្វើបុណ្យទានផ្សេងៗនៅនឹងកន្លែង ឬភូមិកំណើតរបស់ខ្លួនត្រូវរក្សាឱ្យបានល្អ។ បញ្ហាដែលកើតឡើងសម្រាប់ដោះស្រាយជីវិតការរស់នៅជាមួយគ្នាក្នុងសង្គមតូចៗកម្រិតនេះ ក៏មានសារៈសំខាន់ណាស់ដែរសម្រាប់ប្រជាជនទាំងនោះ។ ការអភិវឌ្ឍតាមទីកន្លែងមានភាពជាក់ស្តែងងាយមើលឃើញ និងទាញយកផលដោយផ្ទាល់សម្រាប់ប្រជាជនដែលនៅក្នុងភូមិនោះ។ យើងឃើញថាវាជាផលប្រយោជន៍តាមទីកន្លែងដែលផ្សេងពីផលប្រយោជន៍ទូទៅ។ ផលប្រយោជន៍តាមទីកន្លែងនេះវាមានលក្ខណៈស្មុគស្មាញ ហើយដែលពុំអាចគ្រប់គ្រងដោយអាជ្ញាធររដ្ឋបានទេ ផ្ទុយទៅវិញមានតែរាស្ត្រប្រជាខ្លួនឯងផ្ទាល់ទេដែលយល់ដឹងពីស្ថានភាពជាក់ស្តែងហើយអាចដោះស្រាយបញ្ហាដោយខ្លួនឯងបាន។

ដូច្នេះបញ្ហាវិមជ្ឈការដែនដីនេះទទួលស្គាល់លទ្ធិប្រជាធិបតេយ្យ និងសេរីភាវូបនីយកម្មគេតែងទទួលស្គាល់ឱ្យមានការគ្រប់គ្រងផលប្រយោជន៍រាស្ត្រតាមទីកន្លែងដោយរាស្ត្រខ្លួនឯង។

**អំណាចរាស្ត្រ**

អំណាចរបស់រាស្ត្រត្រូវបានប្រើប្រាស់តាមរយៈតំណាងរបស់ខ្លួន ហើយដែលតំណាងរបស់រាស្ត្រនេះកើតឡើងពីការបោះឆ្នោតជ្រើសតាំងផ្អែកតាមលទ្ធិប្រជាធិបតេយ្យ។

**លទ្ធិប្រជាធិបតេយ្យ**

តាមឆន្ទៈនៃអំណាចរដ្ឋ គេធ្វើច្បាប់សម្រាប់បង្កើតអង្គការដឹកនាំដែលគេហៅថាក្រុមប្រឹក្សា (សភា) មួយដែលជាអង្គការសម្រេចធំបំផុតនៅដែនដីមួយ(រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់)។ ក្រុមប្រឹក្សានេះមានអំណាចបញ្ញត្តិចេញជាវិធានក្នុងការរៀបចំ និងការប្រព្រឹត្តទៅនៃសមូហភាពដើម្បីផលប្រយោជន៍រួមរបស់សមូហភាពខ្លួន។ ប៉ុន្តែសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា (សភា) មានច្រើន ឬតិចអាស្រ័យលើច្បាប់អង្គការកំណត់ឱ្យប៉ុណ្ណោះ។ ក្រុមប្រឹក្សាដែលជាអង្គការក្នុងការសម្រេចធ្វើអ្វីមួយឱ្យស្របទៅនឹងបំណងប្រាថ្នារបស់រាស្ត្រនៃសមូហភាពខ្លួន បើពុំដូចនេះទេរាស្ត្រនឹងដកសេចក្តីទុកចិត្ត ហើយសម្រេចបោះឆ្នោតឱ្យអ្នកថ្មីជំនួសនៅអាណត្តិបន្ទាប់ជាមិនខាន។

## ផ្នែកទី ២ ៖ ប្រភេទនៃប្រព័ន្ធវិមជ្ឈការ

មិនមានការកំណត់ប្រភេទវិមជ្ឈការឱ្យបានច្បាស់លាស់ និងឯកភាពគ្នាទេ នៅក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវពីវិមជ្ឈការ និងអង្គការអន្តរជាតិដែលធ្វើការងារពាក់ព័ន្ធនឹងវិមជ្ឈការ។ ការធ្វើវិមជ្ឈការទៀតសោតមានលក្ខណៈស្មុកស្មាញបន្តិចដោយសារតែមានការផ្ទេរអំណាចពីថ្នាក់លើទៅថ្នាក់ក្រោម ពីដែនដីធំទៅដែនដីតូចនៅ

អង្គភាពតែមួយ ឬពីអង្គភាពមួយទៅអង្គភាពមួយទៀត។ ជាទូទៅវិមជ្ឈការត្រូវបានបែងចែកជា ៣ ប្រភេទគឺ វិមជ្ឈការនយោបាយ វិមជ្ឈការរដ្ឋបាល និងវិមជ្ឈការសារពើពន្ធ។[3]

### ២.១ ៖ វិមជ្ឈការនយោបាយ

វិមជ្ឈការនយោបាយសំដៅលើការផ្ទេរឆន្ទានុសិទ្ធិ ឬអំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្តពាក់ព័ន្ធនឹងកិច្ចការមូលដ្ឋានទៅឱ្យប្រជាពលរដ្ឋ ឬតំណាងរបស់ប្រជាពលរដ្ឋ (រដ្ឋាភិបាលមូលដ្ឋាន "Local govement") តាមរយៈប្រជាធិបតេយ្យូបនីយកម្ម (Démocratisation)។ តាមទ្រឹស្ដីការធ្វើសេចក្ដីសម្រេចផ្សេងៗដោយថ្នាក់ មូលដ្ឋានគឺល្អប្រសើរជាងការធ្វើសេចក្ដីសម្រេចពីថ្នាក់ជាតិ ពីព្រោះរដ្ឋាភិបាលមូលដ្ឋាននៅជិតប្រជាពលរដ្ឋស្គាល់ពីតម្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅមូលដ្ឋានជាងថ្នាក់ជាតិ។ ឆន្ទានុសិទ្ធិ ឬអំណាចនោះជាស្វ័យភាពដែលផ្ដល់ឱ្យមូលដ្ឋានដោយរដ្ឋធម្មនុញ្ញ ឬច្បាប់។ វាមិនត្រូវបានត្រួតពិនិត្យ ឬជំទាស់ដោយថ្នាក់ កណ្ដាលឡើយ លើកលែងតែវាធ្វើ ឡើងដោយផ្ទុយនិងរដ្ឋធម្មនុញ្ញ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត។ តំណាងរបស់ប្រជាពលរដ្ឋដែលទទួលបានអំណាចនោះត្រូវតែជា តំណាងដែលចេញពីការបោះឆ្នោតចេញពីប្រជាពលរដ្ឋមិនមែនតែងតាំង ឬចាត់តាំងដោយរដ្ឋាភិបាលកណ្ដាលឡើយ។ ក្នុងការអនុវត្តវិមជ្ឈការនយោបាយ បានពេញលេញបើកផ្លូវឱ្យប្រជាពលរដ្ឋអាចចូលរួមដំណើរការតាក់តែងគោលនយោបាយ និងសម្រេចកិច្ចការមូលដ្ឋាន។ វិមជ្ឈការនយោបាយ (Political Décentralisation អាចមានអត្ថន័យប្រហាក់ប្រហែលនឹងពាក្យ home-rule, self-governig, self-government, self-determination, political autonomy, or local autonomy)។[4]

### ២.២ ៖ វិមជ្ឈការរដ្ឋបាល

វិមជ្ឈការរដ្ឋបាល សំដៅលើការផ្ទេរមុខងារ ឬការទទួលខុសត្រូវមួយចំនួនពីថ្នាក់ជាតិទៅអង្គភាពថ្នាក់ក្រោម ឬអង្គភាពផ្សេងៗទៀត។ មុខងារ ឬការទទួលខុសត្រូវទាំងនោះអាចនឹងត្រូវត្រួតពិនិត្យ ឬដកហូតយកត្រឡប់ទៅវិញដោយថ្នាក់ជាតិនៅពេលអនុវត្តផ្ទុយពី ច្បាប់ឬគោលដៅផ្ដល់ឱ្យ។ យោងទៅតាមធនាគារពិភពលោកវិមជ្ឈការមាន៣លក្ខណៈគឺ វិសហមជ្ឈការ(Déconcentration) ការធ្វើប្រតិភូកម្ម (Délégation) និងការផ្ទេរ (Dévolution)។

### ២.៣ ៖ វិមជ្ឈការសារពើពន្ធ

វិមជ្ឈការសារពើពន្ធ សំដៅលើការបែងចែកចំណូល និងចំណាយរបស់រដ្ឋរវាងថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន។ វិមជ្ឈការសារពើពន្ធមិនមែនសំដៅតែលើការផ្ទេរអំណាចសារពើពន្ធ ធនធាន សារពើពន្ធនោះទេ ប៉ុន្តែ

---

[3] ឯកសារស្ដីពី" ទ្រឹស្ដីវិមជ្ឈការ" របស់លោក ហួត ស៊ីនាថ ស្លាយទី៧ នៃឯកសារសម្រាប់បង្រៀនសិស្សមន្ត្រីក្រមការជំនាន់ទី៤ នៃសាលាភូមិន្ទរដ្ឋបាល (១៥.តុលា. ២០១០)។

[4] ឯកសារស្ដីពី" ទ្រឹស្ដីវិមជ្ឈការ" របស់លោក ហួត ស៊ីនាថ ស្លាយទី៨ ដល់ទី១០ នៃឯកសារសម្រាប់បង្រៀនសិស្សមន្ត្រីក្រមការជំនាន់ទី៤ នៃសាលាភូមិន្ទរដ្ឋបាល (១៥.តុលា. ២០១០)។

រួមទាំងសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងចាត់ចែងអំណាចទាំងនោះដែរ។ វិមជ្ឈការសារពើពន្ធ ជាផ្នែកមួយដ៏សំខាន់របស់វិមជ្ឈការ ព្រោះដើម្បីឱ្យអង្គវិមជ្ឈការបំពេញមុខងារប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ចាំបាច់ត្រូវទទួលបានធនធានគ្រប់គ្រាន់។[5] វិមជ្ឈការសារពើពដែលមានាក់ទំនងយ៉ាងជិតស្និតជាមួយនឹងកម្មវិធីកំណែទម្រង់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយទិសដៅនៃកំណែទម្រង់នេះនៅ ដំណាក់កាល ទី២ (២០០៨-២០១០) គឺដើម្បី "**ពង្រឹង និងអភិវឌ្ឍន៍គោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការសារពើពន្ធ**" ដោយធានាឱ្យបានការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងពិចារណាអំពីគណនេយ្យភាព។ ចំណែកនៅថ្នាក់ឃុំ សង្កាត់វិញសកម្មភាពកំណែទម្រង់ការគ្រប់គ្រងសេវាសាធារណៈដែលបានគ្រោងមានបំណងកែលម្អ រៀបចំ និងការអនុវត្តថវិកា ក៏ដូចជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលនាំទៅដល់ការប្រមូលចំណូលសារពើពន្ធឱ្យកាន់តែខ្ពស់។[6]

## ផ្នែកទី ៣ ៖ គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើវិមជ្ឈការ

### ៣.១ ៖ គុណសម្បត្តិ

ក្នុងប្រវត្តិសាស្ត្ររបស់ជាតិមួយចាំបាច់ត្រូវតែធ្វើយ៉ាងណាឱ្យមានឯកភាពជាតិ។ ការកាត់បន្ថយអំណាចរដ្ឋបាលកណ្តាល គឺជាស្ថាប័នសេរីនិយមដែលធ្វើឱ្យមានការអនុវត្តសេរីភាពនៅមូលដ្ឋាន។

ប្រព័ន្ធនេះធ្វើឱ្យមានតម្លៃគោលការណ៍លទ្ធិប្រជាធិបតេយ្យដោយអនុញ្ញាតឱ្យមានការចូលរួមពីប្រជាជន ឬអ្នកតំណាងរបស់មូលដ្ឋានក្នុងកិច្ចការនយោបាយ។ ម៉្យាងទៀតប្រព័ន្ធវិមជ្ឈការនេះបានផ្តល់ផលប្រយោជន៍ជាច្រើនដូចជា៖

- ពង្រឹងការឆ្លើយតបឱ្យបានរហ័សរបស់ស្ថាប័នរាជរដ្ឋាភិបាលនានា
- បង្កើនលំហូរព័ត៌មានរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ
- ធ្វើឱ្យសម្រេចបានកិច្ចប្រឹងប្រែងថ្មីផ្នែកនយោបាយ
- ពង្រឹងលទ្ធិប្រជាធិបតេយ្យកម្រិតថ្នាក់ជាតិ
- កាត់បន្ថយកម្រិតចំណាយទូទៅរបស់រដ្ឋាភិបាល
- ជំរុញការទទួលខុសត្រូវឱ្យកាន់តែប្រសើរឡើង ព្រមទាំងទប់ស្កាត់ភាពលម្អៀងនានា។

### ៣.២ ៖ គុណវិបត្តិ

ការផ្ទេរអំណាចកណ្តាលខ្លាំងពេកធ្វើឱ្យមានផលអាក្រក់ជាច្រើន៖

[5] ឯកសារស្តីពី" ទ្រឹស្តីវិម្បការ" របស់លោក ហួត ស៊ីនាថ ស្លាយទី៨ ដល់ ទី១២ នៃឯកសារសម្រាប់បង្រៀនសិស្សមន្ត្រីក្រមការជំនាន់ទី៤ នៃសាលាភូមិន្ទរដ្ឋបាល (១៥.តុលា. ២០១០)។

[6] សៀវភៅ **នីតិរដ្ឋបាលទូទៅ** របស់សាស្ត្រាចារ្យ **ហៀង សាង** បោះពុម្ពលើកទី១ ឆ្នាំ២០១១ ទំព័រទី ១១០ (កំណាត់ចំណាំ)។

- ការធ្វើឱ្យមានគ្រោះថ្នាក់ត្រង់ថាបានដាក់ឯកភាពជាតិ និងសាមគ្គីភាពរបស់ប្រទេសឱ្យស្ថិតក្នុងគ្រោះកាចដោយការរីកចម្រើននៃលទ្ធភាពរបស់មូលដ្ឋាន។
- ការធ្វើឱ្យបែកខ្ញែកខ្វះខ្វាយឯកសារចាំបាច់របស់រដ្ឋបាល គឺដោយសារការអនុវត្តវិធានការរដ្ឋបាលខុសៗគ្នាតាមមណ្ឌលនៃមូលដ្ឋាននីមួយៗ។
- ការធ្វើឱ្យធ្វេសប្រហែសមិនគិតថាអាជ្ញាធរតាមមូលដ្ឋានខ្វះខាតជាញយៗសមត្ថកិច្ចបច្ចេកទេស និងបទពិសោធន៍ជាចាំបាច់។
- ឃើញថាការបន្ថយអំណាចរដ្ឋបាលកណ្តាលធ្វើឱ្យមានករណីមួយចំនួនដូចជា៖ ការបោះបង់ចោលផលប្រយោជន៍រួមរបស់ប្រជាជាតិដោយចាប់យកផលប្រយោជន៍តាមមូលដ្ឋានទៅវិញ។

# ជំពូកទី ២
# រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ឃុំ សង្កាត់

ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះត្រូវអនុវត្តតាមបែបវិមជ្ឈការមានអត្ថន័យថា គឺជាការផ្ទេរអំណាច មុខងារ ការទទួលខុសត្រូវ និងធនធានមួយចំនួនពីរដ្ឋបាលកណ្តាលមករដ្ឋបាលថ្នាក់មូលដ្ឋាន។ ដូចនេះឃុំសង្កាត់ត្រូវរៀបចំឱ្យមានការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ ដើម្បីឱ្យមានតម្លាភាពក្នុងផ្ទេរអំណាចនេះ។

## ផ្នែកទី១ ៖ ការរៀបចំក្រុមប្រឹក្សាឃុំ សង្កាត់

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកើតចេញពីការបោះឆ្នោត ហើយមានតួនាទីគោរព និងអនុវត្តតាមការណែនាំពីថ្នាក់លើតាមឋានានុក្រម។

### ១.១ ៖ ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងឃុំ និងមានសកម្មភាពបម្រើប្រយោជន៍ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សង្កាត់របស់ខ្លួនដោយការរៀបចំសណ្តាប់ធ្នាប់ និងមានសមាជិកពី ៥នាក់ ទៅ ១១នាក់ដោយយោងតាមស្ថានភាពប្រជាសាស្ត្រ និងភូមិសាស្ត្រ។ ម៉្យាងទៀតចំនួនសមាជិកជាក់ស្តែង និងការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាដែលត្រូវបានកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយសមាជិកនេះមានអាណត្តិ៥ឆ្នាំ និងត្រូវផុតកំណត់ទៅវិញនៅពេលដែលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។[7]

### ១.២ ៖ ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់

#### ក. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់

ការបោះឆ្នោត ត្រូវធ្វើតាមប្រព័ន្ធសមាមាត្រជាសាកល សម្ងាត់ សេរី យុត្តិធម៌ និងសមភាពដោយកើតចេញពីឆន្ទៈផ្ទាល់របស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់នោះ។ ការបោះឆ្នោតត្រូវធ្វើក្នុងរយៈពេល ៥ឆ្នាំម្តងដែលមានកាលបរិច្ឆេទនៅថ្ងៃតែមួយនៅទូទាំងប្រទេស។ ការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

#### ខ. លក្ខខណ្ឌបេក្ខជនឈរឈ្មោះបោះឆ្នោត

ដើម្បីមានសិទ្ធិក្នុងការឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចជា៖ មានសញ្ជាតិខ្មែរពីកំណើត ចេះអាន និងសរសេរអក្សរខ្មែរបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះមានអាយុយ៉ាងតិច២៥ឆ្នាំដល់ថ្ងៃបោះឆ្នោតមាន

[7] មាត្រា ១៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

លក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដែលត្រូវបានកំណត់តាមច្បាប់។ [8] បេក្ខជនត្រូវមានឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះរបស់គណបក្សនយោបាយណាមួយ ហើយបេក្ខជនម្នាក់ៗត្រូវតែមានឈ្មោះនៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ។[9]

### គ. បុគ្គលដែលគ្មានសិទ្ធិឈរឈ្មោះ

បុគ្គលដែលគ្មានសិទ្ធិឈរឈ្មោះមានដូចជា ៖ ក្រុមប្រឹក្សាធម្មនុញ្ញ ចៅក្រម ប្រតិភូរាជរដ្ឋាភិបាល អភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ មន្ត្រីពាក់ព័ន្ធនឹងការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ដូចជា៖ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែងព្រះសង្ឃ ឬបុព្វជិត សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន និងស្មៀនឃុំ សង្កាត់ណាមួយ។

### ឃ. ការតែងតាំងក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។ នៅក្នុងដំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សា ឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសម្រួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ។[10] ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសពីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេ ហើយជាបេក្ខជនដែលមានលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជន។ ជំទប់ទី១ និងចៅសង្កាត់រងទី១ ត្រូវបានជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលទទួលបានសម្លេងឆ្នោតលំដាប់ថ្នាក់ទី២។ ចំណែកជំទប់ទី២ និងចៅសង្កាត់រងទី២ គឺត្រូវជ្រើសរើសចេញពីបញ្ជីជាប់ឆ្នោតលំដាប់ទី៣។[11]

សរុបមកការតែងតាំងក្រុមប្រឹក្សានេះបានទាល់តែបេក្ខជនមានសម្លេងសន្លឹកឆ្នោតគាំទ្រច្រើនជាងគេ និងត្រូវតែងតាំងជាប្រធានក្រុមប្រឹក្សាតែម្តងតាមរយៈប្រកាសរបស់ក្រសួងមហាផ្ទៃ ដែលអភិបាលស្រុក ខណ្ឌជាអ្នកធ្វើអធិបតីក្នុងពិធីតែងតាំង និងប្រគល់ត្រាជូនប្រធានក្រុមប្រឹក្សា ដើម្បីសម្រេចកិច្ចការនានាក្នុងមូលដ្ឋានរបស់ខ្លួន។

### ១. តួនាទីរបស់ឃុំ សង្កាត់

តួនាទីបំរើកិច្ចការក្នុងមូលដ្ឋានសម្រាប់បំរើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់

[8] មាត្រា ១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់។

[9] មាត្រា ២,៩៨,៩៩នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់។

[10] មាត្រា១៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

[11] មាត្រា១៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ខ្លួនត្រូវធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅតាមទីសាធារណៈ។[12] ការរៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវកិច្ចការទាំងនោះឱ្យដំណើរការល្អ លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋព្រមទាំងជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ការពារថែរក្សា បរិស្ថាន ធនធានធម្មជាតិ វប្បធម៌ និងបេតិកភណ្ឌជាតិសម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក និងបំពេញកិច្ចការទូទៅដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ហើយមានតួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬប្រគល់អំណាចរបស់អាជ្ញាធររដ្ឋបាលឃុំ សង្កាត់មានភារកិច្ច អនុវត្តតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។[13] ក្នុងករណីនេះអាជ្ញាធររដ្ឋបានធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់មកការបង្កើនសមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈថវិកាសម្រាប់អនុវត្ត។

*__ចំណាំ__ ប្រតិភូកម្មអំណាចខាងលើនេះត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ គឺថាការធ្វើប្រតិភូកម្មនេះមិនមែនឱ្យតែបុគ្គលណាមួយ ឬចំពោះតែប្រធាន ក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់នោះទេ។

**ឧទាហរណ៍:** ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់។

### ២. សិទ្ធិអំណាចរបស់ឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។

- អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ គឺថាត្រូវធ្វើតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងសិទ្ធិអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់ធ្វើឡើងតាម រយៈការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់តាមស្មារតីរដ្ឋធម្មនុញ្ញផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតនានាដែលពាក់ព័ន្ធឡើយ។
- អំណាចខាងឃុំ សង្កាត់មានន័យថា រដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួនក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់ប្រគល់ឱ្យតាមរយៈប្រតិភូកម្មពីក្រុមប្រឹក្សាឃុំ សង្កាត់

[12] មាត្រា១៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[13] មាត្រា ៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

តាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មដល់មេឃុំ ចៅសង្កាត់ជាអ្នកអនុវត្ត។

*ចំណាំ ករណីដែលមិនអាចធ្វើប្រតិភូកម្មឱ្យមេឃុំ ចៅសង្កាត់បានមានដូចជា៖ ព្រៃឈើ ប្រៃសណីយ៍ និងទូរគមនាគមន៍ការពារប្រទេស សន្តិសុខជាតិនយោបាយក្រៅប្រទេសគោលនយោបាយសារពើពន្ធ។[14]

## ផ្នែកទី ២ ៖ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នត្រូវអនុវត្តតាមបែបវិមជ្ឈការដែលជាការផ្ទេរអំណាចមុខងារ ការទទួលខុសត្រូវ និងធនធានមួយចំនួនពីរដ្ឋបាលកណ្តាលឱ្យទៅរដ្ឋបាលថ្នាក់មូលដ្ឋានតាមរយៈការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ។

ឃុំ សង្កាត់ ជាសមូហភាពវិមជ្ឈការដែលទទួលបាននូវស្វ័យភាពក្នុងការគ្រប់គ្រងដែលបាន បញ្ជាក់ពីលទ្ធិប្រជាធិបតេយ្យក្នុងថ្នាក់មូលដ្ឋាន។ ដូច្នេះហើយក៏តម្រូវឱ្យប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានជំនួយការពីរូបគឺ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ គណៈកម្មាធិការ និងស្មៀនឃុំ សង្កាត់ព្រមទាំងមេភូមិផង គឺត្រូវដើរតួយ៉ាងសំខាន់បំផុតក្នុងការគ្រប់គ្រងឃុំ សង្កាត់។[15]

### ២.១ ៖ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួនដោយផ្អែកតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

#### ក. មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់គឺជា ប្រធានក្រុមប្រឹក្សា ហើយគាត់ក៏ជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែរពីព្រោះគាត់ត្រូវបានជ្រើសរើសចេញពីការបោះឆ្នោតដែលមានលេខរៀងនៅលើគេបង្អស់ ហើយជាបេក្ខជនដែលមានសំលេងសន្លឹកឆ្នោតច្រើនជាងគេ។

#### ខ. ជំទប់ ឬចៅសង្កាត់រង

ជំទប់ទី១ ទី២ ឬចៅសង្កាត់រងទី១ ទី២ជាជំនួយការរបស់មេឃុំ ចៅសង្កាត់ដែលត្រូវបានជ្រើសរើសពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជន មានលំដាប់ទី២ និងលំដាប់ទី៣។

#### គ. គណៈកម្មាធិការ

គណៈកម្មាធិការ គឺជាអ្នកផ្តល់យោបល់ និងជួយការងារក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនេះត្រូវបានតែងតាំងដោយមេឃុំ ចៅសង្កាត់ដែលមានសមាជិកតិចជាង

[14] មាត្រា ៤៥,៤៨,៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់។

[15] មាត្រា២០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

០៣រូប ដែលបានជ្រើសរើសចេញពីសមាជិកណាម្នាក់ពីក្រុមប្រឹក្សា ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ក្នុងមូលដ្ឋានរបស់ខ្លួនបាន។

**ឃ. ស្មៀនឃុំ សង្កាត់**

ស្មៀនឃុំ សង្កាត់ គឺជាបុគ្គលិកនៃក្រសួងមហាផ្ទៃដែលបានតែងតាំងដោយរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ និងបានប្រឡងជ្រើសរើសពីមន្រ្តីរាជការសិស្សនិស្សិត។ ស្មៀនឃុំ សង្កាត់អាចនឹងត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើពីមេឃុំ ចៅសង្កាត់ដោយអនុលោមតាមសេចក្តីសម្រេចពីសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់តាមសម្លេងភាគច្រើនដាច់ខាត។[16]

**ង. មេភូមិ**

មេភូមិ ជាអ្នកតំណាងឱ្យប្រជាពលរដ្ឋក្នុងភូមិ និងជាសេនាធិការឃុំ សង្កាត់។ មេភូមិត្រូវតែង តាំង អនុប្រធានភូមិ និងសមាជិកភូមិ ដើម្បីជាជំនួយការ។ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិក ភូមិត្រូវតែជាប្រជាពលរដ្ឋក្នុងភូមិនោះផ្ទាល់តែម្តង។

ក្នុងការជ្រើសរើសមេភូមិ ត្រូវអនុលោមតាមមាត្រា៣០ និងមាត្រា៨៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ការរៀបចំជ្រើសរើសមេភូមិត្រូវធ្វើឡើងនៅតែភូមិណាដែលក្រសួងមហាផ្ទៃបានទទួលស្គាល់ជាផ្លូវការតែប៉ុណ្ណោះ។

[16] មាត្រា ២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់។

### គំនូសរចនាសម្ព័ន្ធនៃរដ្ឋបាលឃុំ សង្កាត់




### ២.២ ៖ តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវ

#### ក. មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវអនុវត្តសេចក្ដីសម្រេចបទប្បញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់។[17] ការផ្ទេរសិទ្ធិឱ្យជំទប់ ចៅសង្កាត់រងពេលខ្លួនអវត្តមាន និងចាត់តាំងគណៈកម្មាធិការ ដើម្បីពិគ្រោះយោបល់ និងជួយកិច្ចការនានា។ ព្រមទាំងផ្ដល់យោបល់ និង រាយការណ៍ជូនក្រុមប្រឹក្សាពីសកម្មភាពការងារ រៀបចំផែនការ ហិរញ្ញវត្ថុ ចាត់ចែងអនុវត្តតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ព្រមទាំងកិច្ចការផ្សេងៗ ដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ។[18]

[17] មាត្រា ២២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

[18] មាត្រា ៣៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងក្រុមប្រឹក្សាឃុំ សង្កាត់។

**ខ. ជំទប់ ឬចៅសង្កាត់រង**

-ជំទប់ទី១ ចៅសង្កាត់រងទី១

ជំទប់ទី១ ចៅសង្កាត់រងទី ១ ត្រូវទទួលកិច្ចការមេឃុំ ចៅសង្កាត់លើភារកិច្ចសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលភារកិច្ចបន្ថែមទៀតពីមេឃុំ ចៅសង្កាត់ និងបំពេញការងារជាមេឃុំ ចៅសង្កាត់ស្ដីទីក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមាន។

-ជំទប់ទី២ ចៅសង្កាត់រងទី២

ត្រូវជួបមេឃុំ ចៅសង្កាត់ការងារ ផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងបំពេញការងារជាមេឃុំ ចៅសង្កាត់ស្ដីទីក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ ចៅសង្កាត់ រងទី១អវត្តមាន។ ម្យ៉ាងទៀតមេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមទៀតដល់ជំទប់ទី២ ចៅសង្កាត់រងទី២។

**គ. គណៈកម្មាធិការ**

គណៈកម្មាធិការមានតួនាទីផ្ដល់យោបល់ជួយការងារក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការកសាងផែនការ និងថវិកាព្រមទាំងរាយការណ៍ពីការវិវត្តន៍ការងារប្រចាំខែរបស់ខ្លួន និងផ្ដល់យោបល់វិធានការត្រូវអនុវត្តដែលពាក់ព័ន្ធនឹងការងារ។

**ឃ. ស្មៀនឃុំ សង្កាត់**

ទោះបីស្មៀនឃុំ សង្កាត់ជាបុគ្គលិកស្ថិតក្នុងក្របខ័ណ្ឌរដ្ឋបាលរបស់ក្រសួងមហាផ្ទៃក៏ពិតមែន ប៉ុន្តែក្នុងការអនុវត្តការងារ ស្មៀនឃុំ សង្កាត់ត្រូវស្ថិតក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ដូច្នេះស្មៀនឃុំ សង្កាត់មានតួនាទីជួយក្រុមប្រឹក្សាបំពេញមុខងារ និងតួនាទីស្របតាមច្បាប់ជួយរៀបចំ និងអនុវត្តកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ និងរៀបចំឱ្យមានក្ដារខៀនព័ត៌មានមួយ ឬច្រើនដើម្បីបិទផ្សាយសេចក្ដីជូនដំណឹង សេចក្ដីសម្រេច និងលិខិតបទ ដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ សម្រាប់ឱ្យសាធារណៈជនទូទៅបានដឹងព័ត៌មានទាំងនោះ។

**ង. មេភូមិ**

គាត់តួនាទីទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន និងធ្វើជាអ្នកតំណាងឱ្យប្រជាពលរដ្ឋទាំងអស់នៅក្នុងភូមិនឹងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងឃុំសង្កាត់ត្រូវបង្កើនការពិគ្រោះយោបល់ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ ធ្វើសេចក្ដីរាយការណ៍ពីបញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងចូលរួមកិច្ចប្រជុំគណៈកម្មាធិការលើកិច្ចការភូមិអំពីតម្រូវការ និងផលប្រយោជន៍ភូមិ។ ម៉្យាងទៀតមេភូមិត្រូវផ្ដល់យោបល់ដល់ គណៈកម្មាធិការ កសាងផែនការ និងថវិកាឃុំ សង្កាត់លើតម្រូវការ និងអាទិភាពរបស់ភូមិដើម្បីបញ្ចូលទៅក្នុងផែនការ

អភិវឌ្ឍឃុំ សង្កាត់ អនុវត្ត ផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួនត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។[19]

[19] មាត្រា ១១ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

# ជំពូកទី៣
# កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ផ្នែកទី ១ ៖ គោលការណ៍គ្រឹះ

### ១.១ ៖ ចក្ខុវិស័យ

រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្ពោះទៅសម្រេច ចក្ខុវិស័យ៖ "ប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្ដល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូអភិវឌ្ឍដែលអាចជឿទុកចិត្ត បានសំដៅដល់ការបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង"។[20]

### ១.២ ៖ គោលបំណង

ផ្អែកលើចក្ខុវិស័យខាងលើគោលបំណងសំខាន់ៗត្រូវបានកំណត់ និងត្រូវសម្រេចឱ្យបានក្នុងនោះរួច មាន៖ សេវាសាធារណៈប្រកបដោយគុណភាពមានភាពសាមញ្ញប្រសិទ្ធភាព អាចជឿទុកចិត្តបាន និងមានភាព ឆាប់រហ័សក្នុងការឆ្លើយតបទាន់ពេលវេលានឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានភាពងាយស្រួល និង មានការចូលរួមពីអ្នកប្រើប្រាស់សេវាដែរ ហើយក៏មានគោលដៅកំណត់គោលការណ៍ យន្តការ បែបបទនីតិវិធី ប្រភេទសេវារយៈពេល និងកម្រៃនៃការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។[21] ការគ្រប់គ្រង និងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានសមត្ថភាព ប្រសិទ្ធភាព និងភាពជឿទុកចិត្តក្នុងការផ្ដល់សេវាសាធារណៈ ដោយប្រកាន់ភ្ជាប់វប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្ដីភាព និងមនសិការវិជ្ជាជីវៈ។

ប្រព័ន្ធបៀវត្សដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធិភាពការងារ ព្រមទាំងធានាបាន សន្តិភាព រវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។

### ១.៣ ៖ គោលដៅ

ដើម្បីសម្រេចឱ្យបានគោលបំណងខាងលើ កំណែទម្រង់នេះបានកំណត់គោលដៅជាក់លាក់ដូចខាង ក្រោម៖

#### ក. សេវាសធារណៈ

សេវាសាធារណៈត្រូវធ្វើការកែលម្អ ដោយត្រូវសម្រេចឱ្យដល់គោលដៅក្នុងការផ្ដល់សេវាដែលផ្ដោតលើ សេចក្ដីត្រូវការជាក់ស្ដែង និងផ្ដល់សេវាឱ្យចំទីកន្លែងដើម្បីធានាភាពងាយស្រួលដល់អ្នកប្រើប្រាស់ក្នុងការទទួលយ កសេវាទៅប្រើប្រាស់។ លើសពីនេះ ដើម្បីកែលម្អគុណភាព ប្រសិទ្ធភាព និងលើកកម្ពស់តម្លាភាព ព្រមទាំងមាន ការទទួលខុសត្រូវក្នុងការផ្ដល់សេវា។ រដ្ឋបាលឃុំ សង្កាត់ ត្រូវផ្ដល់សេវារដ្ឋបាលតាមប្រភេទសេវា កម្រៃ រយៈ

[20] កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ:២០១៥-២០១៨

[21] មាត្រា ២ នៃអនុក្រឹត្យស្ដីពីការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ពេលនៃការផ្តល់សេវា និងសុពលភាពនៃការផ្តល់សេវាដែលពាក់ព័ន្ធនឹងសេវាអត្រានុកូលដ្ឋាន និងលិខិតអនុញ្ញាត្តមួយចំនួនដែលមិនមែនជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[22]

**ខ. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សត្រូវធ្វើការកែលម្អដោយត្រូវសម្រេចឱ្យដល់គោលដៅក្នុងការលើកកម្ពស់គុណផលការទទួលខុសត្រូវការអភិវឌ្ឍសមត្ថភាពការងារការពង្រឹងសីលធម៌ និងវិន័យមន្ត្រីរាជការស៊ីវិលរួមទាំងរៀបចំតួនាទី ភារកិច្ច របៀបគ្រប់គ្រងជំនាញចាត់ចែងការងារឱ្យមានភាពច្បាស់លាស់ និងចំនួនមន្ត្រីឲ្យឆ្លើយតបនឹងសេចក្តីត្រូវការ។

**គ. បៀវត្ស និងប្រាក់ឧបត្ថម្ភ**

ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់ឧបត្ថម្ភរបស់មន្ត្រីរាជការត្រូវសម្រេចបានឱ្យក្នុងការរៀបចំប្រព័ន្ធបៀវត្សដែលធានាបានសមធម៌ការផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការទាន់ពេលវេលាដល់ដៃ និងគ្រប់ចំនួនដោយបង្រួមគម្លាតបៀវត្សអតិបរមា អប្បបរមា និងលើកទឹកចិត្តផ្អែកលើសមិទ្ធកម្មព្រមទាំងគាំទ្រវិស័យអាទិភាពរបស់រដ្ឋាភិបាលដូចជា វិស័យអប់រំ និងសុខាភិបាល។ យ៉ាងណាមិញការបង្កើនបៀវត្សប្រកបដោយចីរភាពផ្អែកលើស្ថានភាពនៃកំណើនសេដ្ឋកិច្ច និងលទ្ធភាពទ្រទ្រង់បានថវិកាក្នុងការកែលម្អរចនាសម្ព័ន្ធនៃបៀវត្ស ដើម្បីធានាសន្តិភាពរវាងបៀវត្សមន្ត្រីរាជការស៊ីវិល និងបៀវត្សកងកម្លាំងប្រដាប់អាវុធ។

**១.៤ៈ យុទ្ធសាស្ត្រ**

យុទ្ធសាស្ត្រសម្រាប់ការកែទម្រង់ផ្នែកខាងលើត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដើម្បីសម្រេចគោលដៅដែលបានកំណត់។

**ក. សេវាសាធារណៈ**

យុទ្ធសាស្ត្រក្នុងការកែលម្អសេវាសាធារណៈឱ្យបានល្អប្រសើរគឺ ជម្រុញឱ្យមានការផ្លាស់ប្តូរទស្សនាទានក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាសាធារណៈរបស់មន្ត្រីរាជការពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវាព្រមទាំងផ្តល់តម្លៃដល់អ្នកប្រើប្រាស់សេវាផងដែរ។ ជាងនេះទៅទៀត ការកែទម្រង់របៀបរបបការងារពីរចនាសម្ព័ន្ធការងារទៅជារចនាសម្ព័ន្ធប្រតិបត្តិការដោយលើកកម្ពស់គុណភាពសេវាផ្នែកជួរមុខ ព្រមទាំងបង្កើនសមត្ថភាពផ្នែកទ្រទ្រង់នៅជួរក្រោយ។

[22] មាត្រា ១៦ នៃអនុក្រឹត្យស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

យុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍធនធានមនុស្សគឺការផ្តល់ការបណ្តុះបណ្តាល លើកកម្ពស់គុណភាពការបណ្តុះបណ្តាល និងអនុវត្តប្រព័ន្ធគុណផល ដើម្បីពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្ត ការគ្រប់គ្រងធនធានមនុស្សក្នុងន័យធ្វើឱ្យការអភិវឌ្ឍសមត្ថភាពការងារដែលមានស្រាប់ និងអភិវឌ្ឍ សមត្ថភាព ការងារថ្មីក៏ដូចជាធ្វើឱ្យមានភាពប្រសើរឡើងប្រព័ន្ធការងារក្នុងអង្គភាព និងការគ្រប់គ្រងមន្ត្រី។

**គ. បៀវត្ស និងប្រាក់ឧបត្ថម្ភ**

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមមានការរៀបចំប្រព័ន្ធចំណាត់ថ្នាក់ និងតារាងសន្ទស្សន៍បៀវត្សថ្មីព្រមទាំងប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗដើម្បីគាំទ្រការបំពេញការងារ របស់មន្ត្រីរាជការ ដើម្បីកាត់បន្ថយគម្លាតបៀវត្សរវាងបៀវត្សអតិបរមា និងអប្បបរមាឱ្យមកនៅត្រឹមពី៣ ទៅ៣,៥ដង និងការរៀបចំសន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងាររបស់នគរបាលជាតិ យោធិនឱ្យមានសង្គតិភាព នឹងប្រព័ន្ធបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ព្រមទាំងដំឡើងប្រាក់បៀវត្សដោយផ្អែកលើផលិតភាព កំណើនសេដ្ឋកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

**១.៥ ៖ បញ្ហាប្រឈម និងដំណោះស្រាយ**

ទន្ទឹមនឹងសមិទ្ធផលធំៗដែលសម្រេចបានក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ រដ្ឋបាលសាធារណៈបញ្ហា ប្រឈមសំខាន់ៗមួយចំនួនក្នុងរដ្ឋបាលសាធារណៈដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងដោះស្រាយ មានដូចខាងក្រោម៖

**ក. សេវាសាធារណៈ**

យើងកត់សម្គាល់ឃើញថានីតិវិធីមួយចំនួនក្នុងសេវាធារណៈនៅតែមានភាពស្មុកស្មាញ ការប្រមូលផ្តុំ ការិយាធិបតេយ្យ យន្តការនិងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពនៃសេវាសាធារណៈមិនទាន់បាន ដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាពទេ។ ទន្ទឹមនឹងនេះការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងរដ្ឋបាលនៅមាន កម្រិតហើយការរៀបចំ និងការដាក់ឱ្យអនុវត្តមួយចំនួនមានលក្ខណៈដាច់ដោយដុំ មិនមានលក្ខណៈជាប្រព័ន្ធ។ ចំណុចសំខាន់ក្នុងការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាធារណៈ គឺតាមរយៈការបន្ត ការអនុវត្ត គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ និងការអនុវត្តឯកសារណែនាំស្តីពីស្តង់ដារសេវាសាធារណៈដើម្បី បង្កើនភាពឆ្លើយតប ជំនឿទុកចិត្តពីអ្នកប្រើប្រាស់ ប្រសិទ្ធភាព និងប្រសិទ្ធផល។ ដើម្បីពង្រឹងគុណភាព និង ប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលបានអនុម័តឯកសារស្តីពីស្តង់ដាសេវា សាធារណៈដែល មានសូចនាករគោល **ចំនួន៥** ដើម្បីធ្វើឱ្យប្រសើរឡើងកម្រិតនៃភាពឆ្លើយតបជំនឿទុកចិត្ត ប្រសិទ្ធភាព និងប្រសិទ្ធ ផលនៃសេវាធារណៈ។ សូចនាករគោលទាំង៥ នៃស្តង់ដាសេវាធារណៈនោះរួមមាន៖

- គុណភាពព័ត៌មានដែលផ្តល់ជូនអ្នកប្រើប្រាស់សេវា
- ភាពងាយស្រួលក្នុងការទទួលយកសេវា
- ភាពយកចិត្តទុកដាក់ក្នុងការទទួលអ្នកប្រើប្រាស់សេវា
- សេវាផ្តល់តាមគោលការណ៍កំណត់ និងមានអភិបាលកិច្ចល្អ
- យន្តការព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់។

**ខ. ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស**

បញ្ហាប្រឈមដែលទន់ខ្សោយបំផុត គឺការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងស្ថាប័ននៅមានកម្រិតក្នុងការឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការអភិវឌ្ឍធនធានសមត្ថភាព ការកែលម្អការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សតាមរយៈការជម្រុញអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈដើម្បីលើកកម្ពស់គុណផលមន្រ្តី និងជម្រុញការប្រកាន់ខ្ជាប់វប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ។ ដើម្បីអភិវឌ្ឍសមត្ថភាពកែលម្អការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរាជរដ្ឋាភិបាលបានអនុម័តៈ

គោលនយោបាយធនធានមនុស្សនៅក្នុងរដ្ឋបាលសាធារណៈ គឺដើម្បីបង្កើនគុណផលនៅក្នុងវិស័យ រដ្ឋបាលសាធារណៈ និងផ្លាស់ប្តូរឥរិយាបថមន្រ្តីបណ្តើរៗសំដៅលើកកម្ពស់នូវសេចក្តីថ្លៃថ្នូរ ការលើកទឹកចិត្ត ភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្រ្តីរាជការ។

គោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ គោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈបានកំណត់យុទ្ធសាស្ត្រចំនួន៥ រួមមានៈ

- ធ្វើឱ្យប្រសើរឡើងប្រព័ន្ធការងារក្នុងអង្គភាព និងការគ្រប់គ្រងមន្រ្តី
- ពង្រឹងប្រសិទ្ធភាពនៃដំណើរការអនុវត្តការគ្រប់គ្រងធនធានមនុស្ស
- អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល
- ប្រើប្រាស់ឱ្យកាន់តែល្អប្រសើរឡើងសមត្ថភាពការងារដែលមានស្រាប់ និងអភិវឌ្ឍសមត្ថភាពការងារថ្មី
- ផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល។

**គ. បៀវត្ស និងប្រាក់ឧបត្ថម្ភ**

ប្រព័ន្ធបៀវត្សមិនទាន់ឆ្លើយតបនឹងគោលការណ៍សមធម៌ ប្រសិទ្ធភាព សង្គតិភាព ក្នុងនោះគម្លាតបៀវត្សរបស់មន្រ្តីរាជការស៊ីវិលនៅមានកម្រិតខ្ពស់ ប្រព័ន្ធបៀវត្សរបស់កងកម្លាំងប្រដាប់អាវុធ និងមន្រ្តីរាជការ ស៊ីវិលមិនទាន់មានសង្គតិភាពនឹងគ្នា។ សម្រាប់បញ្ហាប្រឈមនេះនឹងត្រូវដោះស្រាយតាមរយៈការការកែទម្រង់ប្រព័ន្ធបៀវត្សត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗៈ

- ការដំឡើងបៀវត្ស ត្រូវអនុវត្តសមស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច និងលទ្ធភាពទ្រទ្រង់បាននៃថវិកាក្នុងន័យធានាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសរួម
- ការធានាបាននូវសម ការបង្កើនផលិតភាព និងប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ
- ការធានាសង្គតិភាពរវាងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។ ការកែទម្រង់ប្រព័ន្ធបៀវត្សនឹងគាំទ្រប្រសិទ្ធភាព នៃការគ្រប់គ្រងធនធានមនុស្ស និងលើកម្ពស់គុណភាពនៃសេវា សាធារណៈ។

## ផ្នែកទី ២ ៖ គម្រោងថវិកាជាតិ

### ១.១ ៖ ការលើកផែនការយុទ្ធសាស្ត្រថវិកាឃុំ សង្កាត់

ឃុំ សង្កាត់ជានីតិបុគ្គលសាធារណៈ។[23] ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តអាណត្តិរបស់ពួកគេប្រកបដោយប្រសិទ្ធភាពដូចដែលចែងក្នុងច្បាប់។ លើសពីនេះទៀតចំណាយ និងចំណូលនៃរដ្ឋបាលថ្នាក់មូលដ្ឋានត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានដែលបានអនុម័ត ដើម្បីធានាការអភិវឌ្ឍន៍នឹងត្រូវបានអនុវត្តតាមបែបប្រជាធិបតេយ្យ។ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យត្រូវមានភាពតំណាងជាសាធារណៈស្វ័យភាពមូលដ្ឋានការពិគ្រោះយោបល់ និងការចូលរួមឆ្លើយតបនឹងគណនេយ្យភាពលើកកម្ពស់គុណភាពជីវិតពលរដ្ឋមូលដ្ឋានលើកកម្ពស់សមធម៌ តម្លាភាព សេចក្តីថ្លៃថ្នូរ និងវិធានការណ៍ប្រឆាំអំពើពុករលួយ និងការរំលោភអំណាច។

#### ក. ចំណូល

មូលនិធិឃុំ សង្កាត់ គឺជាប្រភពចំណូលសំខាន់បំផុតរបស់ឃុំ សង្កាត់នីមួយៗ។ យោងតាមអនុក្រឹត្យស្តីពីការបង្កើតមូលនិធិឃុំ សង្កាត់ឆ្នាំ២០០២ មូលនិធិនេះចែកចេញជាពីរផ្នែក គឺផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍ។ ផ្នែករដ្ឋបាលមិនត្រូវលើសពី ១/៣ និងផ្នែកអភិវឌ្ឍន៍មិនតិចជាង ២/៣ នៃមូលនិធិសរុប។ ថវិកាផ្ទេរប្រចាំឆ្នាំពីរដ្ឋបាលកណ្តាលទៅឃុំ សង្កាត់នីមួយៗ (មូលនិធិឃុំ សង្កាត់) ត្រូវធ្វើឡើង បីដំណាក់កាល តាមលំដាប់លំដោយគឺ ៥០% ៣០% និង២០% នៃមូលនិធិ។ ការផ្ទេរលើកដំបូងមិនត្រូវយឺតជាងថ្ងៃទី០១ ខែមីនា រីឯការផ្ទេរលើកទី២ មិនត្រូវយឺតជាងថ្ងៃទី០១ ខែមិថុនា និងការផ្ទេរលើកទី៣ មិនត្រូវយឺតជាងថ្ងៃទី០១ ខែកញ្ញា។ ឃុំ សង្កាត់មានសិទ្ធិអំណាចគ្រប់គ្រងហិរញ្ញវត្ថុ និងថវិការបស់ខ្លួន ហើយមានប្រភពចំណូលមួយចំនួន៖

- ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធចំណូលមិនមែនសារពើពន្ធ និងកំម្រៃសេវាផ្សេងៗទៀត។[24]

[23] មាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។
[24] មាត្រា ៧៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។

- ឃុំ សង្កាត់ មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋពីថវិការបស់ខ្លួន (ចំណូលពីមូលនិធិឃុំ សង្កាត់)។[25]
- ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវប្រាក់កម្រៃចំពោះការអនុវត្តតួនាទីភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងណាមួយបានប្រគល់ឱ្យ។[26]

**ខ. ចំណាយ**

មាត្រា១៥ នៃអនុក្រឹត្យស្ដីពីការបង្កើតមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០២ មូលនិធិផ្នែករដ្ឋបាលត្រូវបានប្រើសម្រាប់ការចំណាយដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភសម្រាប់ក្រុមប្រឹក្សា
- ប្រាក់ខែបុគ្គលិកនៅមូលដ្ឋាន និងចំណាយសម្រាប់បុគ្គលិកផ្សេងៗ
- ទិញ ឬជួលអាគារសម្រាប់ក្រុមប្រឹក្សា
- គ្រឿងសង្ហារឹម និងសម្ភារៈការិយាល័យសម្រាប់ក្រុមប្រឹក្សា
- ជួសជុល និងថែទាំរដ្ឋបាលឃុំ សង្កាត់
- ថ្លៃទឹក ភ្លើង
- ទិញ ឬជួលមធ្យោបាយធ្វើដំណើរ
- ប្រេងឥន្ធនៈ ប្រេងម៉ាស៊ីន និងការថែទាំយានជំនិះ... ។ល។

**គ. ដំណើរការថវិការបស់ឃុំ សង្កាត់**

តាមគោលការណ៍ថវិកាឃុំ សង្កាត់ត្រូវរៀបចំ និងអនុម័តជាប្រចាំឆ្នាំ។[27] ថវិកាឃុំ សង្កាត់ ត្រូវអនុលោមតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលត្រូវដំណើរការ បីជំហានដែលរួមមានការរៀបចំការអនុវត្ត និងការត្រួតពិនិត្យថវិកា។ ការរៀបចំថវិកាត្រូវដំណើរការដូចខាងក្រោម៖ ដំបូងមេឃុំ ឬចៅសង្កាត់រៀបចំសេចក្តីព្រាងថវិកាដោយមានការគាំទ្រពីគណៈកម្មាធិការផែនការ និងថវិការបស់ក្រុមប្រឹក្សាឃុំសង្កាត់ ហើយយកសេចក្តីព្រាងនេះដើម្បីសុំការអនុម័តពីក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។ មេឃុំ ឬចៅសង្កាត់ ត្រូវធានាថាដំណើរការនៃការរៀបចំថវិកាត្រូវបានធ្វើឡើងដោយសាធារណៈជន។ ការអនុម័តថវិកានេះមិនត្រូវធ្វើឡើងយឺតជាងថ្ងៃទី៣១ ខែតុលានៃឆ្នាំដែលថវិកានោះបានពង្រាងទេ។ ទីពីរ សេចក្តីព្រាងនៃថវិកាត្រូវដាក់ជូន អភិបាលរាជធានី ខេត្ត ដើម្បីអនុម័ត។ ទោះបីយ៉ាងណាក៏ដោយ ក៏អភិបាលរាជធានី ខេត្ត មិនមានសិទ្ធិបដិសេធផែនការចំណាយដែលបានសម្រេច

[25] មាត្រា ៧៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។

[26] មាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។

[27] វាក្យខណ្ឌទី១ មាត្រា ៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។

ដោយក្រុមប្រឹក្សាឃុំ សង្កាត់នោះទេ។ ជារួមអភិបាលរាជធានី ខេត្តផ្តល់ការគាំទ្រក្នុងការពិនិត្យនីត្យានុកូលភាព ប៉ុណ្ណោះ។ អភិបាលរាជធានី ខេត្តនឹងផ្តល់ការបញ្ជាក់ការអនុម័តនេះជាលាយល័ក្ខអក្សរឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រតនាគារជាតិ និងមន្ទីរសេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុ។ អភិបាលរាជធានី ខេត្តត្រូវអនុម័តសេចក្តីព្រាងថវិកាឃុំ សង្កាត់នោះឱ្យបានមុនថ្ងៃទី០១ ខែមករា។ នៅក្នុងដំណាក់កាលអនុវត្តថវិកា ក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្ត ថវិការបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋាននានា។ រាល់ការអនុវត្ត គម្រោងវិនិយោគឃុំ សង្កាត់ ត្រូវអនុវត្ត តាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងឃុំ សង្កាត់។ ទោះបីជាយ៉ាងក៏ដោយ ក៏ថវិកានេះអាចត្រូវបានធ្វើ វិសោធនកម្មក្នុងឆ្នាំសារពើពន្ធដោយយោងតាមការផ្លាស់ប្តូរលក្ខខ័ណ្ឌ សេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលអាចប៉ះពាល់ ចំណូល និងចំណាយដែលបានព្យាករទុក។ រតនាគារជាតិតម្រូវឱ្យរៀបចំរបាយការណ៍ ហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ ប្រចាំឆ្នាំដែលទុកជាកម្មវត្ថុសម្រាប់ការធ្វើសវនកម្ម និងអធិការកិច្ចដើម្បីធានាឱ្យបានភាពជឿជាក់ តម្លាភាព និង យុត្តធម៌នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ។

### ២.២ ៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធ

ជាមធ្យមគម្រោងវិនិយោគរបស់ឃុំ សង្កាត់ចំនួន១៨០០គម្រោងទូទាំងប្រទេសក្នុងមួយឆ្នាំៗដែលក្នុង នោះ៧០% គឺធ្វើផ្លូវជនបទ ១៥%សម្រាប់ផ្នែកធារាសាស្ត្រ ១៥%សម្រាប់គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដូចជា យេនឌ័រប្រឆាំងមេរោគហ៊ីវ និងជំងឺអេដស៍ការការពារបរិស្ថាន និងបញ្ហាផ្សេងៗទៀត។ ចំណែកឯមូលនិធិដែលជា វិភាជន៍ សម្រាប់ឃុំ សង្កាត់នីមួយៗ មានចំនួនប្រហែល៤០.០០០ ដុល្លាអាមេរិកក្នុងមួយឆ្នាំ។ គម្រោងថវិកាត្រូវ រៀបចំឡើងក្រោមការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ ហើយត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិនិត្យ និងអនុម័ត។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ អនុម័តគម្រោងថវិកាកិច្ចប្រជុំជាសាធារណៈឱ្យបានមុនថ្ងៃទី៣១ ខែតុលា។ ក្រោយពីអភិបាលខេត្ត ក្រុងអនុម័ត ចេញសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរជូនប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ លើគម្រោងថវិកាមកប្រធានក្រុម ប្រឹក្សាអាចយកថវិកានោះមកបែងចែកតាមតម្រូវការនៅក្នុងឃុំ សង្កាត់ដូចជា៖ ជួសជុសផ្លូវលំ សាងសង់ប្រព័ន្ធ ធារាសាស្ត្រ រៀបចំស្តារលូមិនឱ្យមានក្លិនមិនល្អដែលធ្វើឱ្យប៉ះពាល់សុខភាពប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបើកវគ្គ បណ្តុះបណ្តាលទាក់ទងនឹងសុខុមាលភាល របស់ប្រជាពលរដ្ឋរៀបចំសណ្តាប់ធ្នាប់ក្នុងមូលដ្ឋានខ្លួន ក៏ដូចជា រៀបចំភូមិឃុំរបស់ខ្លួនឱ្យមានសោភ័ណ្ឌភាពល្អ និងមានអនាម័យល្អ ។ល។

# សេចក្តីសន្និដ្ឋាន

យោងតាមការស្រាវជ្រាវក្រោមប្រធានបទ កំណែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ ពិតជាមានសារៈសំខាន់ណាស់ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍភូមិឃុំ។ សព្វថ្ងៃរដ្ឋបាលថ្នាក់ឃុំ សង្កាត់ ត្រូវបានយកប្រព័ន្ធវិមជ្ឈការមកអនុវត្តប្រកបដោយតម្លាភាព និងប្រសិទ្ធភាពក្នុងការអនុវត្ត ពីព្រោះការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាល ដែលរដ្ឋបាលកណ្តាលផ្ទេរអំណាចទៅឱ្យរដ្ឋបាលមូលដ្ឋាន (រដ្ឋបាលឃុំ-សង្កាត់)។ ការផ្ទេរអំណាចបែបនេះមានគោលបំណងឱ្យរដ្ឋបាលមូលដ្ឋានទទួលខុសត្រូវលើកិច្ចការណាដែលជាផលប្រយោជន៍របស់ខ្លួនដែរ។ ជាការពិតណាស់ ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការនេះ មានខ្លឹមសារជាការអនុវត្តលទ្ធិប្រជាធិបតេយ្យជម្រុញឱ្យមានអភិបាលកិច្ចល្អ និងលើកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ ប្រជាពលរដ្ឋដោយសាររដ្ឋអំណាចបានធ្វើការផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ។ នៅក្នុងកាលានុវត្តភាពនេះរដ្ឋអាចស្គាល់ និងជ្រួតជ្រាបពីការលំបាកទុក្ខធុរៈ និងតម្រូវការរបស់ប្រជារាស្ត្រដែលជាហេតុធ្វើឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ និងកែលម្អយុទ្ធសាស្ត្រដឹកនាំឱ្យកាន់តែមានប្រសិទ្ធភាព។

ក្រោយពីបានធ្វើការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ សង្កាត់) បីវិស័យធំៗ មាន៖ កំណែទម្រង់វិស័យសាធារណៈការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗជាច្រើនទៀត។ យើងសង្កេតឃើញថារដ្ឋបាលថ្នាក់ឃុំ សង្កាត់មានភាពផ្លាស់ប្តូរ និងប្រែប្រួលច្រើនគួរឱ្យកត់សម្គាល់ព្រមទាំងប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងផ្តល់អត្ថប្រយោជន៍ជូនប្រជាពលរដ្ឋក្នុងសង្គមជាតិទាំងមូល។ យ៉ាងណាមិញគោលបំណងសំខាន់ដែលរាជរដ្ឋាភិបាលធ្វើការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិបាន គឺការធ្វើឡើងដើម្បីធានានិរន្តរភាពនៃការផ្តល់សេវាសាធារណៈដោយផ្អែកតាមទិសដៅយុទ្ធសាស្ត្រ និងចក្ខុវិស័យដោយរាជរដ្ឋាភិបាលរំពឹងទុកដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានជាចំបង។ ការអនុវត្តនយោបាយកំណែទម្រង់នៅកម្ពុជាបានឈានដល់ដំណាក់កាល នៃការធ្វើកំណែទម្រង់ដែលមានលក្ខណៈកាន់តែស៊ីជម្រៅស្របតាមគោលដៅរបស់រាជរដ្ឋាភិបាលការធ្វើកំណែទម្រង់បែបនេះតម្រូវឱ្យមានការផ្លាស់ប្តូរទម្លាប់ និងរបៀបរបបនៃការប្រតិបត្តិមួយចំនួនហើយការផ្លាស់ប្តូរនេះតែងជួបនូវការជំនះនឹងការប្រឈម ឬឧបសគ្គជាច្រើនដោយជៀសមិនផុត។ ដើម្បីសម្រេចជោគជ័យបញ្ហាប្រឈមនឹងឧបសគ្គទាំងអស់នេះរដ្ឋត្រូវតែជម្រុញការងារកំណែទម្រង់រដ្ឋបាលសាធារណៈដោយចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរផ្នត់គំនិតអាកប្បកិរិយារបស់មន្ត្រីបើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការឱ្យបានសមស្រប ដើម្បីបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ និងការផ្លាស់ប្តូរការបើកប្រាក់បៀវត្សដោយផ្ទាល់តាមប្រព័ន្ធអេឡិត្រូនិច ( ATM ) ដើម្បីភាពងាយស្រួល។ ទន្ទឹមនឹងនេះយើងឃើញថាការធ្វើកំណែទម្រង់នេះនៅតែបន្តទទួលបានលទ្ធផលល្អ និងដំណើរការបានយ៉ាងរលូនព្រមទាំងមានការជឿជាក់ពីសំណាក់ប្រជាពលរដ្ឋជាទូទៅផងដែរ។

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាយ៉ាងច្រើនក្នុងពេលកន្លងមកទៅលើប្រធានបទយើងក៏បានសង្កេតឃើញនូវចំនុចខ្វះខាតដែលជាគុណវិបត្តិមួយចំនួន និងចំនុចល្អដែលជាគុណសម្បត្តិមួយចំនួនផងដែរ គឺដូចដែលបានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានខាងលើផងដែរ។

ដោយសង្កេតឃើញនូវចំណុចអវិជ្ជមាននៃការកែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ខាងលើនេះ ដើម្បីអនុវត្តន៍ដំណើរការកែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ឱ្យមានប្រសិទ្ធភាព នាងខ្ញុំសូមធ្វើការផ្តល់នូវមតិយោបល់មួយចំនួនដោយបែងចែកជាចំនុចសំខាន់ៗ ដូចរៀបរាប់ខាងក្រោម៖

**ចំណុចខ្សោយ**

- ការយល់ដឹងពីប្រជាពលរដ្ឋនៅមានកម្រិត ជាពិសេសផ្នែកអេឡិចត្រូនិច
- ការចែករំលែកនូវចំណេះដឹង ឬឯកសាររបស់ស្ថាប័នអនុវត្តច្បាប់ គឺនៅមានកម្រិត
- ការកែទម្រង់នៅមានចន្លោះខ្វះខាតទាំងផ្នែកវិស័យសាធារណៈ ធនធានមនុស្ស និងបៀវត្ស
- ចំណេះដឹងមន្ត្រីសាធារណៈនៅមានកម្រិត
- ថវិកាដែលទទួលបានស្ថាប័នរដ្ឋបាលថ្នាក់ជាតិមិនទាន់សមាត្រនឹងតម្រូវការ

**ចំណុចខ្លាំង**

- ការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ
- ការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិបានចេញជាអនុក្រឹត្យប្រកាសជាសាធារណៈ
- ផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ ដោយការបង្វិតសេវាសាធារណៈឱ្យខិតជាប្រជាពលរដ្ឋប្រែក្លាយរដ្ឋបាលសាធារណៈឱ្យទៅជាអ្នកផ្តល់សេវាសាធារណៈវិញ
- បង្កើនលំហូរព័ត៌មានរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ
- កាត់បន្ថយកម្រិតចំណាយទូទៅរបស់រដ្ឋាភិបាល
- មានការទទួលខុសត្រូវឱ្យកាន់តែប្រសើរឡើង ព្រមទាំងទប់ស្កាត់ភាពលម្អៀង។

**ដំណោះស្រាយ**

- ចំណុចសំខាន់ក្នុងការពង្រឹងគុណភាព និងប្រសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ គឺតាមរយៈការបន្តអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈនិងអនុវត្តឯកសារណែនាំពីស្តង់ដារសេវាសាធារណៈដែលមានសូចនាករចំនួន៥(គុណភាពព័ត៌មាន និងភាពយកចិត្តទុកដាក់ដែលផ្តល់ជូនអ្នកប្រើប្រាស់ភាពងាយស្រួលក្នុងការទទួលយកសេវាផ្តល់តាមគោលការណ៍កំណត់ និងមានអភិបាលកិច្ចល្អ យន្តការព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់)

- ដើម្បីបង្កើនគុណផលនៅក្នុងរដ្ឋបាលសាធារណៈ ដើម្បីលើកកម្ពស់គុណផលមន្ត្រី
- ជម្រុញការប្រកាន់ខ្ជាប់វប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ
- ប្រើប្រាស់ឱ្យកាន់តែប្រសើរឡើងសមត្ថភាពការងារដែលមានស្រាប់ និងអភិវឌ្ឍសមត្ថភាពការងារថ្មី
- ផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល
- ការដំឡើងបៀវត្ស ត្រូវអនុវត្តសមស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច និងលទ្ធភាពទ្រទ្រង់បាននៃថវិកាក្នុងន័យធានាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសរួម។

# ឯកសារយោង


- កៅ មុយថង. ២០០៧. *រដ្ឋបាលសាធារណៈទំនើប*. ភ្នំពេញ។
- ក្រសួងមហាផ្ទៃ, ២០១១, *សៀវភៅណែនាំ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលក្រុង*, ភ្នំពេញ។
- ក្រុមការងារអន្តរក្រសួង. ២០០៧. *សេចក្តីណែនាំ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់។*
- គណៈកម្មធិការជាតិដឹកនាំ. ២០០៩. *សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។*
- រាជរដ្ឋាភិបាលកំណែទម្រង់. ២០០៩។
- សុខ សុទ្ធី. ២០១០ ២០១៩. *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិ រយៈពេល១០ឆ្នាំ* . ភ្នំពេញ។
- សេចក្តីណែនាំស្តីពីការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, លេខ០២ ស ណ ន ឆ្នាំ២០១៨ ។
- ហៀង សាង. ២០១៥. *នីតិរដ្ឋបាលទូទៅ* . បោះពុម្ពលើកទី៣. ភ្នំពេញ។
- ឡាញ់ ដា. ២០១៦. *ហិរញ្ញវត្ថុសាធារណៈ* ។
- ឧទ្ទេសនាមដោយ ឯកឧត្តម ឈួន ឆាម. ២០១៥. *កំណែទម្រង់រដ្ឋបាលសាធារណៈ*. ភ្នំពេញ។
- អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់, លេខ:១៦អនក្រ.បក, ២៥ កុម្ភៈ ២០០២។
- អ្នកនិពន្ធអនាមិក. ២០១០. *ស្តីពី កំណែទម្រង់រដ្ឋបាលចំណាយប្រតិបត្តិការអាទិភាព ប្រតិបត្តិការជំរឿន និងរាប់មន្ត្រី រាជការស៊ីវិល*. ភ្នំពេញ។
- គណៈកម្មកាធិការជាតិសម្រាប់ការអភិវឌ្ឍនតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. ២០១៥. *សៀវភៅណែនាំស្តីពី ការអភិវឌ្ឍស្ថាប័នសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ*. ភ្នំពេញ. https://www.interior.gov.kh (បោះពុម្ពលើកទី ២ ខែកក្កដា ឆ្នាំ២០១៥)។